**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល**
**(ខេមបូឌា) ភីអិលស៊ី**

*រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣*

# សេចក្តីជូនដំណឹង
# ស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់
# ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុន **ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី** (ក្រុមហ៊ុន "**ហ្គ្រេន ធ្វីន**" ឬ "**ហ.ធ.អ**") ជាក្រុមហ៊ុនឯកជនដំបូងបង្អស់ ដែលចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា ("**ផ.ម.ក**") មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន និងសាធារណៈជនទាំងអស់ មេត្តាជ្រាបថា ៖ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ ទៅតាមកាលបរិច្ឆេទកំណត់ ដូចខាងក្រោម ៖

១. កាលបរិច្ឆេទកំណត់ទុកៈ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣
២. កាលបរិច្ឆេទនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ៈ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣
៣. ទីកន្លែងប្រារព្ធមហាសន្និបាតភាគហ៊ុនិក លើកទី៩ៈ ទីស្នាក់ការក្រុមហ៊ុន
៤. របៀបវារៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ មានដូចខាងក្រោមៈ

| | |
|---|---|
| ម៉ោង ៨:00 - ៩:00 | ការចុះឈ្មោះ |
| ម៉ោង ៩:00 - ៩:១៥ | ប្រកាសហេតុ |
| ម៉ោង ៩:១៥ - ១០:00 | បទបង្ហាញស្តីពីរបាយការណ៍លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន |
| ម៉ោង ១០:00 - ១០:១៥ | សម្រាកពិសាអាហារសម្រន់ |
| ម៉ោង ១០:១៥ - ១១:00 | ការបោះឆ្នោតបន្តអាណត្តិក្រុមប្រឹក្សាភិបាល |
| ម៉ោង ១១:00 - ១១:៣០ | ការបោះឆ្នោតបែងចែកភាគលាភ និងប្រាក់បំណាច់អភិបាល |
| ម៉ោង ១១:៣០ | មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ |

**<u>បញ្ជាក់</u>ៈ**

១- ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ (កាលបរិច្ឆេទកំណត់ទុក) មានសិទ្ធចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។

២- ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ ត្រូវបញ្ជាក់ការចូលរួមកិច្ច ប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ ជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់ពីថ្ងៃទី០៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ នៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ម៉ោង ៤:០០ ល្ងាច។

៣- ភាគហ៊ុនិកដែលមិនបានបញ្ជាក់ការចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី តាមការកំណត់ខាងលើ នឹងមិនមានសិទ្ធិចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ឡើយ។

ព័ត៌មានបន្ថែមសូមទាក់ទងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាភ្នាក់ងារចុះបញ្ជីផ្ទេរ និងទូទាត់មូលបត្ររបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដូចខាងក្រោម៖

- អាសយដ្ឋាន: អាគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥)១៥-៩០០ ៥៣៨
- អ៊ីម៉ែល: huot.sophy@acledabank.com.kh
- ទូរសារ: (៨៥៥)១៥ ៨០០ ៦៦៣
- អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- ទូរស័ព្ទដៃ: (៨៥៥)៦១-២៨៧ ៧៦៦
- អ៊ីម៉ែល: op.rtp@acledabank.com.kh

ក្រុមហ៊ុន **ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី**